## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម៖**

១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និង អង្គការពាក់ព័ន្ធដែលចូលរួមផ្ទាល់ចំនួន២៦រូប និងតាមប្រព័ន្ធអនឡាយចំនួន៤០រូប សរុបចំនួន៦៦រូប។

**៤. របៀបវារៈ៖**

១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

២-បទបង្ហាញស្តីពីការសិក្សាវាយតម្លៃកម្មវិធីបង្ការមេរោគអេដស៍និងជំងឺអេដស៍ បង្ហាញដោយ **លោកវេជ្ជបណ្ឌិត អ៊ឹង សុវណ្ណៈ** អនុប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ។

៣-មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសរបស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិកសមាជិកា នៃកិច្ចប្រជុំ និងបានបញ្ជាក់ថា ជំងឺអេដស៍នៅតែជាចំណុចអាទិភាព ជាទិសដៅគួរឱ្យបារម្ភគឺ៩៥ ទី១ ដែល

មិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។ ហេតុដូច្នេះ តើយើងគួររកវិធីសាស្ត្រ ឬមធ្យោបាយយ៉ាងណា ដើម្បីសម្រេចគោលដៅ៩៥ទី១ នៅឆ្នាំ២០២៥។ បទអន្តរាគមន៍បង្ការដែលមានលក្ខណៈសុក្រឹតជាក់លាក់ ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលាដែលផ្តោតទៅលើគោលនយោបាយលុបបំបាត់ការឆ្លងរីករាលដាលនៃមេរោគអេស៍ និងជំងឺអេដស៍៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។

តាមរយៈនៃកិច្ចប្រជុំ **លោកវេជ្ជបណ្ឌិត អ៊ឹង សុវណ្ណៈ** អនុប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ បានធ្វើបទបង្ហាញអំពីការសិក្សាវាយតម្លៃកម្មវិធីបង្ការមេរោគអេដស៍និងជំងឺអេដស៍។

សង្ខេបការចម្លងមេរោគអេដស៍និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០២៣ សរុបចំនួន ៧៦,០០០នាក់ ទទួលជោគជ័យលើការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ហើយនៅចុងឆ្នាំ២០២៣នេះ កម្ពុជាសម្រេចបាន៨៩%លើគោលដៅ៩៥ទីមួយ កម្រិត៩៨%លើគោលដៅ៩៥ទីពីរ និងកម្រិត៩៨%លើគោលដៅ៩៥ទីបី។ ដូចនេះគោលដៅដែលបានកំណត់ទាំង៣បញ្ជាក់ថា គោលដៅ៩៥%ទីមួយមិនទាន់សម្រេចបាននៅឡើយ ទាមទារការប្រឹងប្រែងដែលមានលក្ខណៈខុសប្លែកពីមុន ដូចជាការកសាងសមត្ថភាពទាក់ទងនឹងភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងភាពជាដៃគូ ព្រមទាំងការបង្កើនការវិនិយោគជាដើម។

- តាមការសិក្សាស្រាវជ្រាវទៅលើយុវវ័យអាយុចាប់ពី១៥ទៅ២៤ឆ្នាំ នៅចន្លោះពីឆ្នាំ២០១០ដល់ ២០២៣ មានការថយចុះ៣៥% ក្នុងនោះស្ត្រីមានការថយចុះ៦៨% និងបុរសមានការកើនឡើង១១% បើយើងសង្កេតមើលអាយុចន្លោះ១៥ឆ្នាំឡើងទៅ ការឆ្លងថ្មីលើស្ត្រីមាន៤៥% និងបុរសមាន៤២%។
- ការប្រើប្រាស់ឱសថ PrEp មានការប្រើប្រាស់តាំងពីត្រីមាសទី១ឆ្នាំ២០២១ រហូតមកដល់ត្រីមាសទី២ ឆ្នាំ២០២៤នេះ មានការប្រើប្រាស់៤២កន្លែង និងមានចំនួនអ្នកប្រើ២២,៨២២នាក់។
- ការធ្វើតេស្តដោយខ្លួនឯង យុវវ័យដែលមានអាយុពី១៥ឆ្នាំ ទៅ២៤ឆ្នាំ មានចំនួន៥៨៤នាក់ និងចាប់ពី១៥ឆ្នាំឡើងទៅមានចំនួន១,៨២៥នាក់។
- ការធ្វើតេស្តដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៅត្រីមាសទី១ឆ្នាំ២០២៤ ដែលមានអាយុពី ១៥ឆ្នាំទៅ២៤ឆ្នាំ មានចំនួន៤,១២៩នាក់ មានវិជ្ជមាន៥៩៧នាក់ មានអ្នកឆ្លងថ្មី៥០នាក់ស្មើ ៨% និងចាប់ពី១៥ឆ្នាំឡើងទៅមានចំនួន១៦,១៨៧នាក់ មានវិជ្ជមាន២,៤៤៥នាក់ មានអ្នកឆ្លងថ្មី១០៩នាក់ស្មើ៤%។
- ការផ្តល់ដំណឹងដល់ដៃគូមកធ្វើតេស្តនៅត្រីមាសទី១ ឆ្នាំ២០២៤ ដែលមានអាយុពី១៥ឆ្នាំទៅ ២៤ឆ្នាំមានចំនួន១,៧១៣នាក់ មានវិជ្ជមាន៥២នាក់។
- ការព្យាបាលមាន៧៤កន្លែង និងមានអ្នកមកទទួលសេវាចំនួន៦៨,៨០២នាក់។

- បទអន្តរាគន៍មិនមែនសុខាភិបាលយើងសង្កេតឃើញថា ក្រសួងភាគច្រើនមានផែនការបញ្ជ្រាប ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងក្រសួង ដោយមានការបណ្តុះបណ្តាល សិក្ខាសាលា ការផ្សព្វផ្សាយដល់មន្ត្រីនៅក្នុងក្រសួង មន្ត្រីថ្នាក់ក្រោមជាតិ និងបានបញ្ចូលកម្មវិធីអេដស៍ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាទំនើបដូចជាទូរស័ព្ទ និងកម្មវិធីផ្សេងៗ ព្រមទាំងផ្តល់ប័ណ្ណក្រីក្រ ប័ណ្ណសមធម៌ មិនតែប៉ុណ្ណោះបានអប់រំដល់អ្នកនៅពន្ធនាគារ ធ្វើតេស្ត និងបញ្ជូនទៅព្យាបាលក្នុងករណីចាំបាច់។
- ការចំណាយថវិកាទៅលើបទអន្តរាគមន៍បង្ការតាំងពីឆ្នាំ២០១១ មកដល់ឆ្នាំ២០២២ គឺមានការថយចុះពី១៤,២៧២លាន មកនៅត្រឹម៣,៧១៩លានប៉ុណ្ណោះ។
- ផលប៉ះពាល់នៃគម្លាតបទអន្តរាគមន៍បង្ការ គោលបំណងកាត់បន្ថយការចម្លងថ្មីក្នុង១ឆ្នាំឱ្យតិចជាង២៥០នាក់នៅឆ្នាំ២០២៥។ ជាក់ស្តែងសព្វថ្ងៃតាមការប៉ាន់ប្រមាណឃើញថា មានការឆ្លងថ្មីមានចំនួន១,២០០នាក់ ពិសេសលើយុវវ័យប្រឈមមុខខ្ពស់ដែលមានអាយុចាប់ពី ១៥ឆ្នាំដល់២៤ឆ្នាំ ភាគច្រើននៃអ្នកផ្ទុកមេរោគអេដស៍មិនបានមកពិនិត្យរករោគវិនិច្ឆ័យ ជាពិសេសក្រុមបុរសស្រឡាញ់បុរស។ បទអន្តរាគមន៍បង្ការគឺផ្តែកទៅលើការចូលរួមបញ្ចប់អេដស៍ ការបង្កើនផ្តល់ឱសថ PrEP ការបង្កើនសកម្មភាពមិនមែនសុខាភិបាល។

**ដើម្បីឱ្យមានប្រសិទ្ធភាពយើងត្រូវដោះស្រាយទៅលើ៖**ប្រជាជនដែលជាអ្នកផ្ទុកមេរោគអេដស៍មិនបានធ្វើរោគវិនិច្ឆ័យ ដូចជាពួកចំណាកស្រុក តំបន់ដាច់ស្រយាលដែលមានកន្លែងកម្សាន្តសប្បាយឱ្យមានទូរស័ព្ទ បង្កើនសកម្មភាពផ្តល់សេវាកម្ម ពង្រីកដោយគ្មានការរើសអើងមាក់ងាយ គោរពសិទ្ធ តាមដានអ្នកអនុវត្តច្បាប់ ផ្សព្វផ្សាយទៅដល់អ្នកធ្វើច្បាប់ និងភ្នាក់ងារអនុវត្តច្បាប់ ពង្រីកការបង្ការនៅក្នុងផ្នែកមិនមែនសុខាភិបាល ប្រជាជននៅក្នុងភូមិសាស្ត្រ។

**ការផ្តល់អនុសាសន៍**

- ការផ្តល់បទអន្តរាគមន៍បង្ការដល់ក្រុមគោលដៅ
- ជំរុញការទាមទារបទអន្តរាគមន៍សុខាភិបាល
- ជ្រើសរើស និងបណ្តុះបណ្តាលដល់មន្ត្រីមានសមត្ថភាព បន្ថែមដល់បុគ្គលិកធ្វើការផ្សព្វផ្សាយដើម្បីធ្វើការអប់រំ និងផ្តល់សេវាបង្ការមេរោគអេដស៍ប្រកបដោយប្រសិទ្ធភាព។
- ជំរុញឱ្យកាន់តែស៊ីជម្រៅនូវតួនាទីនៃភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពិសេសឱ្យយល់ពីតួនាទីបទអន្តរាគមន៍មេរោគអេដស៍និងជំងឺអេដស៍ និងការយល់ដឹងក្នុងចំណោមមន្ត្រីរបស់ស្ថាប័ន។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ ជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងកំណត់យកថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)៕

ថ្ងៃចន្ទ ១៤រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥

**បានពិនិត្យត្រឹមត្រូវ**

ជ.**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

អ្នកធ្វើរបាយការណ៍

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម យិនដារ៉េត**

**ស៊ុំ ផល្លា**